ម៉ាថាយ១:១-១៥

***ឆាទចនា*** *ពង្សាវតាពីព្រះយេស៊ូវគ្រីស្ទ កំណត់ត្រាការប្រសូតនៃព្រះយេស៊ូវ ពីនាងព្រហ្មចារី*

## ពង្សាវតាពីព្រះយេស៊ូវគ្រីស្ទ

ព្រះគម្ពីរដំណឹងល្អតាមលោកម៉ាថាយ ក៏ដូចជាគម្ពីរសញ្ញាថ្មីដែរ ចាប់ផ្តើមឡើងជាមួយនឹងបញ្ជីពង្សាវតារនៃពួកព្ធយុកោដែលមានវង្សត្រកូលជាបន្តបន្ទាប់រហូតមកដល់ព្រះយេស៊ូវគ្រីស្ទប្រសូតមកក្នុងលោកយើងនេះ។ បញ្ជីពង្សាវតារនេះ មានសារៈសំខាន់បំផុត នៅក្នុងព្រះបន្ទូលទាំងមូល។ ព្រះគម្ពីរទាមទារយ៉ាងតឹងរ៉ឹងអស្ចារ្យអំពីភាពសុក្រឹតក្នុងការកត់ត្រាហេតុការណ៍ទាំងឡាយ រួមទាំងឈ្មោះមនុស្សដែលរួមចំណែកនៅក្នុងបញ្ជីពង្សាវតារនៃព្រះយេស៊ូវគ្រីស្ទ។ បញ្ជីពង្សាវតារនេះ ចែកចេញជាបីផ្នែកធំៗនេះ

ផ្នែកទីមួយ បញ្ជីពង្សាវតារពីលោកអ័ប្រាហាំមកទល់នឹងក្សត្រដាវីឌ(ខ១-ខ៦)។

ផ្នែកទីពីរ បញ្ជីពង្សាវតារពីក្សត្រសាឡូម៉ូន មកទល់នឹងគ្រាដែលកូនចៅយ៉ាកុបត្រូវគេធ្វើនិរទេសទៅឯស្រុកបាប៊ីឡូន (ខ៧-ខ១១)។

ផ្នែកទីបី ពង្សាវតារពីគ្រានិរទេសទៅស្រុកបាប៊ីឡូន មកទល់នឹងលោកយ៉ូសែប

ដែលជាជាងឈើ (៦១២-៦១៧)។

កាលពីពេលដែលយើងសិក្សាកំណត់គម្ពីរលោកុប្បត្តិ យើងបានអោយឈ្មោះគម្ពីរនោះថា ជាគម្ពីររៀបរាប់ពីគ្រួសារ។ ពង្សាវតារមានលក្ខណៈសំខាន់ជាទីបំផុត។ នៅពេលដែលយើងចាប់ផ្តើមសិក្សាព្រះគម្ពីរសញ្ញាថ្មី ក៏យើងឃើញមានរៀបរាប់អំពីពង្សាវតារយ៉ាងដូច្នោះដែរ។

បើតាមយើងមើលមួយភ្លែត យើងឃើញលោកម៉ាថាយ ចាប់ផ្តើមសរសេរឈ្មោះមនុស្សមួយចំនួនធំ ដែលធ្វើអោយយើងពិបាកអាន ហើយអ្នកខ្លះក៏មានចិត្ត ធុញទ្រាន់នឹងចង់អានផងដែរ។ ខ្ញុំនឹកឃើញពេលខ្ញុំជឿព្រះអង្គដំបូង ខ្ញុំចាប់ផ្តើមអានព្រះគម្ពីរម៉ាថាយអស់ដប់ប្រាំពីរជំពូកតែក្នុងមួយពេល។ ប៉ុន្តែមុននឹងខ្ញុំចាប់ផ្តើមអានទាំងដប់ប្រាំពីរជំពូកនោះ ខ្ញុំអានបញ្ជីពង្សាវតារនៃព្រះយេស៊ូវនេះ រួចហើយខ្ញុំគិតថា ហេតុអ្វីបានជាចាំបាច់ត្រូវសរសេរឈ្មោះមនុស្សអីក៏ច្រើនម្ល៉េះ? ភាគច្រើនខ្ញុំអានមិនចំឈ្មោះអ្នកទាំងនោះទេ។ ប៉ុន្តែដោយសារខ្ញុំចង់ដឹងពីដំណឹងល្អនៃព្រះយេស៊ូវពេកបានជា ខ្ញុំចេះតែប្រឹងអានទៅ។ បើប្រសិនណាជាខ្ញុំអោយគម្ពីរនេះ ទៅដល់អ្នកមិនមានចិត្តចង់ជឿនោះ គេច្បាស់ជាមិនអានម៉ាថាយជំពូកមួយ ដែលសម្តែងអំពីបញ្ជីពង្សាវតារនេះទេ ពីព្រោះធ្វើអោយធុញគេទ្រាន់គួរសមដែរ។ ពេលយើងអោយអ្នកជឿថ្មីអានព្រះបន្ទូលព្រះអង្គ គួរអោយគេអានព្រះគម្ពីរដំណឹងល្អបី ដែលមានលូកា ម៉ាកុស យ៉ូហានជាដើមឯព្រះគម្ពីរដែលគួរអោយអានមុនដំបូង គឺព្រះគម្ពីរម៉ាកុស។ បើប្រសិនណាជាអាចធ្វើទៅបានសូមកុំអោយគេអានព្រះគម្ពីរម៉ាថាយមុនដំបូងអោយសោះ។ ប៉ុន្តែសេចក្តីដែលខ្ញុំ

ជំរាបខាងលើនេះ មិនមែនមានន័យថា បញ្ជីពង្សាវតារដែលមាននៅក្នុងព្រះគម្ពីរម៉ាថាយនេះ គ្មានប្រយោជន៍អ្វីសោះនោះទេ។

ព្រះគម្ពីរសញ្ញាថ្មីទាំងមូល ពឹងពាក់អាស្រ័យទាំងស្រុង ទៅលើភាពសុក្រឹតនៃបញ្ជីពង្សាវតារ ពីព្រោះដោយសារបញ្ជីពង្សាវតារនេះហើយ ទើបយើងឃើញព្រះអម្ចាស់យេស៊ូវទ្រង់ពិតជាពូជពង្សរបស់លោកអ័ប្រាហាំ ហើយនិងពិតជាពូជពង្សរបស់ក្សត្រដាវីឌប្រាកដមែន។ លោកអ័ប្រាហាំ និងក្សត្រដាវីឌ ជាបង្គោលស្នឹងរបស់បញ្ជីពង្សាវតារនេះ ហើយឈ្មោះលោកទាំងពីរ មានសារៈសំខាន់យ៉ាងក្រៃលែង។ ឈ្មោះលោកអ័ប្រាហាំមានលក្ខណៈសំខាន់ ពីព្រោះគឺរូបលោកហើយ ដែលជាមេផ្តើមនៃនគរទាំងមូល ឯពង្សាវតាររបស់ក្សត្រដាវីឌវិញ ក៏សំខាន់ដែរ ពីព្រោះទ្រង់ជាក្សត្រទីមួយដែលព្រះជាម្ចាស់សព្វព្រះទ័យ ហើយជារាជវង្ស ដែលមានតាំងពីយូរយារណាស់មកហើយ។

នៅចំពោះជនអ៊ីស្រាអែលវិញ បញ្ជីពង្សាវតារមានសារៈសំខាន់បំផុត ពីព្រោះគេយកបញ្ជីពង្សាវតារមកផ្ទឹមជាមួយនឹងឈ្មោះរបស់មនុស្សទូទៅ ដើម្បីអោយដឹងថាតើគេពិតជាកើតនៅក្នុងវង្សត្រកូលរបស់អ៊ីស្រាអែលមែនឬមិនមែន? យើងឃើញមានឧទាហរណ៍ ពេលដែលជនជាតិអ៊ីស្រាអែលធ្វើមាតុភូមិនិវត្តន៍មកពីស្រុកបាប៊ីឡូនវិញ គម្ពីរអែសរ៉ាបានចែងយ៉ាងដូច្នេះថា "ពួកអ្នកទាំងនោះ បានរកបញ្ជីជាតិរបស់ខ្លួនក្នុងពួកអ្នកដែលបានរាប់តាមពង្សាវតារ តែរកមិនឃើញសោះឡើយ ដូច្នេះគេត្រូវរាប់ទុកដូចជាមានសៅហ្មងហើយ ក៏ត្រូវបណ្តេញចេញពីការងារជាសង្ឃទៅ" (អែសរ៉ា២:៦២)។ នៅ

ពេលដែលអែសរ៉ាត្រឡប់មកពីប្រទេសបាប៊ីឡូន ដើម្បីនាំជនជាតិអ៊ីស្រាអែលមកតាំងទីលំនៅ នៅទីក្រុងយេរូសាឡិមវិញ មានមនុស្សសន្ធឹកណាស់ ធ្វើដំណើរមកតាមលោក ដើម្បីមកតាំងទីលំនៅសារជាថ្មី។ នៅពេលនោះ មានអ្នកខ្លះដែលធ្វើជាសង្ឃនៅក្នុងវិហាររបស់ទីក្រុងយេរូសាឡិម ប៉ុន្តែគេមិនដឹងថាអ្នកនោះត្រូវជាកូនចៅរបស់អ្នកណាទេ។ សង្ឃអែសរ៉ាបានប្រើបញ្ជីជាតិ ដើម្បីរុករកអោយឃើញថា តើសង្ឃទាំងនោះពិតជាជនជាតិអ៊ីស្រាអែល ឬមួយក៏ចេះតែក្លែងបន្លំទេ។

បញ្ជីពង្សាវតារ ឬបញ្ជីជាតិទាំងនោះ ត្រូវរដ្ឋាភិបាលរក្សាទុកនៅក្នុងអគារអគ្រានុកូលដ្ឋាន។ ឯអគារអគ្រានុកូលដ្ឋាននោះ គឺជាអគារមួយដែលស្ថិតនៅក្នុងបរិវេណនៃព្រះវិហារទីក្រុងយេរូសាឡិម។ នៅក្នុងសម័យនោះ វិហារនិងរដ្ឋាភិបាល គឺមានប្រព័ន្ធចូលឆ្លងគ្នាតែមួយសុទ្ធ។ បញ្ជីពង្សាវតារនេះ ត្រូវរក្សាទុកនៅក្នុងព្រះវិហាររហូតទៅដល់ព្រះវិហារនោះ ត្រូវរំលាយចោលនៅក្នុងគ្រឹស្តសករាជឆ្នាំ៧០។ គូសត្រូវរបស់ព្រះយេស៊ូវ ពិតជាទៅឆែកឆេរមើល ថាតើព្រះយេស៊ូវពិតជាកើតនៅក្នុងត្រកូលអ៊ីស្រាអែលមែនឬមិនមែន? ពួកអ្នកទាំងនោះពិតជារកឃើញថា ព្រះយេស៊ូវគ្រីស្ទជាពូជពង្សរបស់ជនជាតិអ៊ីស្រាអែលមែន ដោយមិនអាចប្រកែកបាន។ មូលហេតុដែលគេទៅឆែកឆេរនោះ ពីព្រោះគេចង់ដឹងមូលហេតុពិតប្រាកដថា ការដែលព្រះអម្ចាស់មានបន្ទូលថា ព្រះអង្គជាវង្សត្រកូលរបស់អ័ប្រាហាំ និងជារាជវង្សរបស់ដាវីឌនោះ តើត្រូវមែនឬមិនមែន?

បញ្ជីវង្សត្រកូលមានសារៈសំខាន់ម្យ៉ាងទៀត ពីព្រោះព្រះយេស៊ូវប្រសូតមក

ទទួលនាទីធ្វើជាអ្នកគង្វាលរបស់សាសន៍អ៊ីស្រាអែល។ ព្រះយេស៊ូវបានប្រកាសអង្គទ្រង់ថា ទ្រង់ជាអ្នកគង្វាលចៀមដែលចូលតាមទ្វារ ប៉ុន្តែចោរតែងតែហក់មកចូលក្នុងហ្វូងចៀមតាមផ្លូវផ្សេងវិញ (យ៉ូហាន១០:១-២)។ "ហ្វូងចៀម" គឺជាសាសន៍អ៊ីស្រាអែលទាំងមូលតែម្តង។ ព្រះអង្គមិនបានចូលមកក្នុងហ្វូងចៀមដោយផ្លោះរបងទេ ហើយព្រះអង្គក៏មិនបានចូលមកក្នុងហ្វូងចៀម ដោយតាមច្រកល្អកណាមួយផ្សេងដែរ។ ព្រះអង្គយាងចូលមកក្នុងហ្វូងចៀម គឺសាសន៍អ៊ីស្រាអែលតាមទ្វារត្រឹមត្រូវ។ ទ្រង់ប្រសូតមកតាមវង្សត្រកូលរបស់ក្សត្រដាវីឌ ដែលត្រូវជាខ្សែវង្សត្រកូលរបស់លោកអ័ប្រាហាំ។ ដោយមូលហេតុនេះហើយ បានជាលោកម៉ាថាយចាប់ផ្តើមព្រះគម្ពីរដំណឹងល្អតាមរយៈលោក ដោយបង្ហាញអោយឃើញច្បាស់អំពីពង្សាវតារ ពីព្រះយេស៊ូវគ្រីស្ទ ថាទ្រង់ពិតជាកើតមកតាមទ្វារពង្សាវតារនៃសាសន៍អ៊ីស្រាអែលមែន។ បញ្ជីពង្សាវតារនេះ ក៏មានសារៈសំខាន់ ដើម្បីនឹងបញ្ជាក់ថា សេចក្តីទំនាយនានានៅក្នុងព្រះគម្ពីរសញ្ញាចាស់ បានសម្រេចឡើងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ គូសត្រូវរបស់ព្រះយេស៊ូវគ្រីស្ទ មិនអាចបដិសេធថា ព្រះយេស៊ូវគ្រីស្ទមិនមែនកើតនៅក្នុងបញ្ជីពង្សាវតាររបស់សាសន៍អ៊ីស្រាអែលបានឡើយ។ ដូច្នេះគេត្រូវរកលេសផ្សេងទៀត ដើម្បីបដិសេធថា ព្រះអង្គជាព្រះបដិសេធថាព្រះអង្គជាក្សត្រ ដែលត្រូវយាងមកសោយរាជ្យនៅលើសាសន៍អ៊ីស្រាអែល។

មានលោកគ្រូអធិប្បាយម្នាក់ បានចែករំលែកបទពិសោធន៍របស់លោក ពេលដែលលោកនៅជាយុវជននៅឡើយ។ នៅគ្រាមួយគាត់បានទៅចូលរួមសន្និសីទយុវជន ហើយព្រះជាម្ចាស់ក៏មានបន្ទូលមកកាន់រូបលោក។ លោកគ្រូអធិប្បាយព្រះបន្ទូលពេល

នោះ ធ្វើអោយចិត្តលោកមានសេចក្តីរីករាយជាខ្លាំង។ នៅពេលអធិប្បាយព្រឹកមួយនោះ លោកបានសួរទៅកាន់ពួកយុវជន យុវនារីចំនួនប្រមាណបីរយនាក់ថា “តើអ្នករាល់គ្នាប៉ុន្មាននាក់ ដែលបានអានព្រះគម្ពីរមួយចប់ក្នុង១ឆ្នាំ?” គ្រូអធិប្បាយដែលមានបទពិសោធន៍នោះ គាត់ងាកមើលខេងមើលខាង មិនឃើញមាននរណាម្នាក់លើកដៃសោះ។ គ្រូអធិប្បាយនោះ សួរជាលើកទីបួន ក៏មានយុវជនម្នាក់អង្គុយក្រោយបង្អស់លើកដៃទាំងស្ទាក់ស្ទើរ ហើយក៏ឧទានឡើងថា “ខ្ញុំបានអានព្រះគម្ពីរ ប៉ុន្តែខ្ញុំអានត្រង់ណាដែលខ្ញុំចូលចិត្ត ខ្ញុំមិនចូលចិត្តអានបញ្ជីពង្សាវតារទាល់តែសោះ”។ យុវជនដ៏ទៃទៀតសើច ហើយគេទាំងអស់គ្នានាំគ្នានិយាយថា បញ្ជីពង្សាវតារធ្វើអោយធុញទ្រាន់ណាស់ គ្មាននរណាម្នាក់គេយកចិត្តទុកដាក់នឹងអានទេ។ គ្រូអធិប្បាយដែលពណ៌នារឿងនេះ គាត់បានបញ្ចប់សេចក្តីពណ៌នារបស់គាត់ថា “បើសិនជាព្រះវិញ្ញាណនៃព្រះដាក់ឱ្យមានបញ្ជីពង្សាវតារមកក្នុងព្រះគម្ពីររបស់ព្រះអង្គ ព្រះអង្គមិនមែនអោយសរសេរចុះមកឥតប្រយោជន៍នោះឡើយ។ ព្រះអង្គដាក់បញ្ជីទាំងនោះមក ពីព្រោះមានសារៈសំខាន់ណាស់”។ លោកអ្នកបងប្អូនអើយ បញ្ជីរពង្សាវតារក្នុងព្រះគម្ពីរម៉ាថាយនេះ មានសារៈសំខាន់ជាទីបំផុត ដូចបានជំរាបក្នុងមូលហេតុខាងលើនេះស្រាប់។

បញ្ជីពង្សាវតារ ដែលរៀបរាប់នៅក្នុងព្រះគម្ពីរម៉ាថាយនេះ គឺជាបញ្ជីពង្សាវ-តារ ពីព្រះយេស៊ូវគ្រីស្ទខាងខ្សែលោកយ៉ូសែប។ នៅពេលក្រោយទៀត ដែលយើងសិក្សាព្រះគម្ពីរលូកា យើងនឹងឃើញបញ្ជីពង្សាវតារមួយឈុតទៀត របស់ព្រះយេស៊ូវគ្រីស្ទ ខាងខ្សែនាងម៉ារាម្តង។

### នេះបញ្ជីពង្សាវតារពីព្រះយេស៊ូវគ្រីស្ទ ជាវង្សាហ្លួងដាវីឌនឹងជាជំនួរវង្សនៃលោក អ័ប្រាហាំដែរ (ម៉ាថាយ១:១)។

"នេះបញ្ជីពង្សាវតារពីព្រះយេស៊ូវគ្រីស្ទ"។ ឃ្លានេះ ជាបង្គោលស្នឹងសម្រាប់ព្រះគម្ពីរដំណឹងល្អតាមលោកម៉ាថាយ។ ឃ្លានេះ មិនបានរៀបរាប់នៅទីណាទៀតទេនៅក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូល។ បើប្រសិនណាលោកអ្នកត្រឡប់ទៅព្រះគម្ពីរសញ្ញាចាស់វិញ ហើយចាប់មើលពីព្រះគម្ពីរម៉ាឡាគីបកត្រឡប់ទៅសាការី រហូតទៅដល់គម្ពីរបញ្ចក័ណ្ឌដែលមានចោទិយកថា ជនគណនា លេវីវិន័យ និក្ខមនំ រហូតទៅដល់លោកុប្បត្តិ លោកអ្នកពិបាកនឹងរកឃើញថា មានឃ្លាដែលនិយាយដូចជាព្រះគម្ពីរម៉ាថាយបាននិយាយនេះណាស់។ ប៉ុន្តែកំពុងដែលលោកអ្នកអានព្រះគម្ពីរលោកុប្បត្តិ លោកអ្នកស្រាប់តែឃើញមានឃ្លាស្រដៀងនឹងឃ្លាខាងលើ "នេះជាបញ្ជីពង្សាវតារនៃពួកអ័ដាម..." (លោកុ.៥:១)។ ដូច្នេះនៅក្នុងព្រះគម្ពីរទាំងមូលមានឃ្លានេះចំនួនពីរ មួយគឺជាបញ្ជីពង្សាវតារអ័ដាម ហើយមួយទៀត គឺជាបញ្ជីពង្សាវតារនៃព្រះយេស៊ូវគ្រីស្ទ។ តើត្រូវធ្វើដូចម្តេច ដើម្បី អោយលោកអ្នកកើតនៅក្នុងវង្សត្រកូលរបស់គ្រួសារអ័ដាម? លោកអ្នក មិនចាំបាច់ធ្វើអ្វីទាំងអស់ គឺលោកអ្នកកើតង៉ាមក លោកអ្នកជាវង្សត្រកូលរបស់បញ្ជីពង្សាវតាររបស់លោកតាអ័ដាមស្រាប់។ ប៉ុន្តែលោកអ្នកបងប្អូនអើយ គ្រប់មនុស្សដែលមានឈាមក្រហម ដែលកើតនៅក្នុងត្រកូលអ័ដាម សុទ្ធតែស្ថិតនៅក្នុងបញ្ជីមនុស្សស្លាប់ទេ (រ៉ូម៥:១២)។ បញ្ជីវង្សត្រកូលរបស់អ័ដាម គឺជាបញ្ជីនៃមនុស្សដែល

ត្រូវស្លាប់។

នៅមានបញ្ជីមួយទៀត គឺជាបញ្ជីពង្សាវតារនៃព្រះយេស៊ូវគ្រីស្ទ។ តើធ្វើដូចម្តេច ដើម្បីអោយលោកអ្នកទាំងអស់គ្នាអាចរាប់បញ្ចូលទៅក្នុងបញ្ជីពង្សាវតារនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទបាន? លោកអ្នកបងប្អូនមានសិទ្ធិអាចរាប់បញ្ចូលទៅក្នុងពង្សាវតាររបស់ព្រះយេស៊ូវគ្រីស្ទបានដោយសារការកើតជាថ្មី។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានបង្រៀននៅក្នុងព្រះបន្ទូលព្រះអង្គយ៉ាងដូច្នេះថា យើងគ្រប់គ្នាត្រូវតែកើតជាថ្មីដើម្បីអោយបានឃើញនគរព្រះ (សូមអានយ៉ូហាន៣:៣)។ នៅពេលដែលយើញទាំងអស់គ្នាកើតជាថ្មី ដោយទទួលព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដាក់នៅក្នុងចិត្តរបស់យើង ឈ្មោះរបស់យើងត្រូវដកចេញពីបញ្ជីពង្សាវតាររបស់លោកអ័ដាម ជាបញ្ជីមនុស្សស្លាប់ បញ្ចូលទៅក្នុងបញ្ជីពង្សាវតាររបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលជាបញ្ជីរបស់ពួកមនុស្សរស់។ បញ្ជីរបស់ពួកមនុស្សរស់នេះ ហៅថាបញ្ជីជីវិតរបស់កូនចៀម។ នៅពេលដែលយើងកើតពីផ្ទៃម្តាយយើងតាមធម្មជាតិមកនោះ លោកអ្នកបងប្អូនស្ថិតនៅក្នុងបញ្ជីរបស់លោកអ័ដាម។ នៅពេលដែលខ្ញុំកំពុងនិយាយនេះ ខ្ញុំជឿថា លោកអ្នកបងប្អូនទាំងអស់គ្នាដែលស្តាប់ព្រះបន្ទូល សុទ្ធតែជាអ្នកដែលមានឈ្មោះកត់ទុកនៅក្នុងបញ្ជីជីវិតរបស់កូនចៀមរួចរ ហើយ។

លោកម៉ាថាយបានរៀបរាប់ថា ព្រះយេស៊ូវជា "បុត្ររបស់ដាវីឌ ជាកូនរបស់អ័ប្រាហាំ"។ តើលោកម៉ាថាយមិនបានជ្រាបទេឬអីថា អ័ប្រាហាំបានកើតមកមុនស្តេចដាវីឌឆ្ងាយណាស់! លោកម៉ាថាយជ្រាបច្បាស់អំពីដំណើរនេះ ដូច្នេះហើយ បានជា

លោករៀបរាប់អំពីមនុស្សជាបន្តបន្ទាប់ តាំងពីមុនរៀងរហូតទល់នឹងគ្រាក្រោយនេះ។ បើលោកជ្រាបហើយ ហេតុអ្វីបានជាលោកដាក់នាមដាវីឌមុនអ័ប្រាហាំយ៉ាងដូច្នេះ? លោកដាក់យ៉ាងនេះ ព្រោះលោកចង់សម្តែងប្រាប់យើងទាំងអស់គ្នាថា ព្រះយេស៊ូវគឺជាអង្គសង្គ្រោះ គឺជាព្រះមហាក្សត្រលើអស់ទាំងក្សត្រ ជាអង្គមួយដែលយាងមកបង្កើតស្ថានសួគ៌នៅលើផែនដី។ ព្រះអង្គនោះ ត្រូវតែជាអង្គដំបូងបង្អស់។ ប៉ុន្តែមុននឹងទ្រង់យាងមកធ្វើជាអង្គដំបូងនោះ ព្រះអង្គត្រូវប្រសូតនៅក្នុងវង្សត្រកូលរបស់ដាវីឌ ដូចជាព្រះអម្ចាស់បានទស្សន៍ទាយថា "ព្រះយេស៊ូវគ្រីស្ទត្រូវកើតនៅក្នុងខ្សែត្រកូលរបស់ដាវីឌ"។

## ព្រះយេស៊ូវជារាជបុត្ររបស់ក្សត្រដាវីឌ

ព្រះយេស៊ូវក៏ត្រូវជាកូនរបស់លោកអ័ប្រាហាំដែរ។ ត្រង់ចំណុចនេះ ជាចំណុចសំខាន់បំផុត ពីព្រោះព្រះជាម្ចាស់មានបន្ទូលដល់អ័ប្រាហាំដូច្នេះថា "គ្រប់ទាំងសាសន៍នៅផែនដីនឹងបានពរដោយសារពូជឯង..."(លោកុ.២២:១៨)។ ចំណែកគម្ពីរកាឡាទី ៣:១៦វិញ សាវ័កប៉ូលពន្យល់តទៅទៀតថា "ពូជ" នោះគឺជា "ព្រះគ្រីស្ទ"។ ដូច្នេះព្រះយេស៊ូវគ្រីស្ទ ក៏ជាកូនរបស់លោកអ័ប្រាហាំដែរ។

**[២] អ័ប្រាហាំបង្កើតអ៊ីសាក។បង្កើតយ៉ាកុប។បង្កើតយូដា ហើយនឹងបងប្អូនគាត់ [៣] យូដាយកនាងតាម៉ារ បង្កើតបានពេរេសនឹង**

**សេរ៉ាសពេរេសបង្កើតហេស្រុន។បង្កើតអើរ៉ាម ៤អើរ៉ាមបង្កើត**
**អាំមីនដាប់។បង្កើតណាសូន។បង្កើតសាលម៉ូន ៥សាលម៉ូនយក**
**នាងរ៉ាហាប បង្កើតបានបូអូស។យកនាងរស់បង្កើតបានអូបិឌ។**
**បង្កើតអ៊ីសាយ ៦អ៊ីសាយបង្កើតដាវីឌដ៏ជាស្តេច ស្តេចដាវីឌ**
**យកប្រពន្ធរបស់អ៊ូរីបង្កើតបានសាឡូម៉ូន (ម៉ាថាយ១:២-៦)។**

ការសិក្សាពីបញ្ជីពង្សាវតារនៃព្រះយេស៊ូវគ្រីស្ទ ធ្វើអោយយើងមានចិត្តរំភើបរីករាយថែមទៀត។ នៅក្នុងខខាងលើយើងឃើញមានឈ្មោះបួននាក់ទៀត ដែលរាប់បញ្ចូលមកក្នុងបញ្ជីវង្សាវតារដែលបង្កើតព្រះយេស៊ូវគ្រីស្ទមក។ នៅក្នុងនោះមានឈ្មោះស្រ្តីបន្ថែមផង ហើយមានសាសន៍ដ៏ទៃរាប់បញ្ចូលនៅក្នុងបញ្ជីពង្សាវតារនោះដែរ។

តាមធម្មតាឈ្មោះរបស់ស្រ្តីមិនត្រូវរៀបរាប់ នៅក្នុងបញ្ជីពង្សាវតារនៃសាសន៍ហេព្រើរទេ។ សូមលោកអ្នកបងប្អូនកុំចោទប្រកាន់ខ្ញុំថា ខ្ញុំមើលងាយស្រ្តីអោយសោះនៅត្រង់ចំណុចនេះ។ ប៉ុន្តែនៅក្នុងពេលរៀបការ ទោះបីសព្វថ្ងៃនេះក៏ដោយ គេយកឈ្មោះបុរសធ្វើជាមេគ្រួសារនោះទាំងមូល។ សម័យនេះ ក៏ធ្វើយ៉ាងដូច្នេះ សម័យពីដើមក៏ធ្វើដូច្នោះដែរ។ ខ្ញុំមិនមើលងាយស្រ្តីភេទទេ ប៉ុន្តែខ្ញុំគ្រាន់តែនិយាយពីធាតុពិត ដែលវាកើតឡើងនៅក្នុងសង្គមមនុស្សយើង។ នៅក្នុងសម័យព្រះយេស៊ូវគ្រីស្ទរស់នៅលើផែនដីនេះ បញ្ជីពង្សាវតារនានា កម្រឃើញមានឈ្មោះស្រ្តីចូលណាស់ ប៉ុន្តែទោះបីជាយ៉ាង

នោះក៏ដោយ យើងឃើញមានឈ្មោះស្ត្រីបួនរូប ត្រូវរាប់បញ្ចូលនៅក្នុងពង្សាវតារនោះផង។ ស្ត្រីទាំងបួនរូបនោះ មិនមែនគ្រាន់តែជាស្ត្រីទេ ប៉ុន្តែជាស្ត្រីសាសន៍ដទៃទៅទៀត។ លោកអ្នកបងប្អូនជ្រាបស្រាប់ហើយថា នៅក្នុងច្បាប់របស់ព្រះ ព្រះអង្គមិនអនុញ្ញាតអោយរៀបការជាមួយនឹងអ្នកដែលមិនជឿទេ។ សូម្បីលោកអ័ប្រាហាំ ព្រះអម្ចាស់ទ្រង់មានបន្ទូលអោយ ទៅរកភរិយាអោយកូនលោកនៅស្រុកកំណើត ពីព្រោះពូជពង្សរបស់លោកភាគច្រើនជាអ្នកជឿដល់ព្រះជាម្ចាស់។ នៅក្នុងដំណើររឿងយ៉ាកុបក៏ដូច្នេះដែរ។ ព្រះជាម្ចាស់ចង់អោយខ្សែស្រឡាយដែលបង្កើតព្រះយេស៊ូវគ្រីស្ទ សុទ្ធតែជាខ្សែស្រឡាយដែលជឿដល់ព្រះអង្គ។ យើងឃើញមានឈ្មោះស្ត្រីបួនរូប សុទ្ធតែជាស្ត្រីសាសន៍ដទៃ ស្ត្រីពីររូបជាសាសន៍កាណាន ហើយស្ត្រីមួយរូបជាសាសន៍ម៉ូអាប់ ហើយស្ត្រីមួយរូបទៀតជាសាសន៍ហេត។ លោកអ្នកច្បាស់ជាសួរថា ហេតុអ្វីបានជាស្ត្រីសាសន៍ដទៃទាំងនោះ មានចំណែកនៅក្នុងបញ្ជីពង្សាវតារនៃព្រះយេស៊ូវគ្រីស្ទដែរ?

"នាងតាម៉ារ" ជាស្ត្រីទីមួយដែលជាសាសន៍ដទៃ អោយរាប់បញ្ចូលទៅក្នុងពង្សាវតាររបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សាច់រឿងនៅក្នុងគម្ពីរលោកុប្បត្តិជំពូកសាមសិបប្រាំបី ជាសាច់រឿងដែលយើងមើលទៅ មិនគួរអោយមានរៀបរាប់នៅក្នុងព្រះគម្ពីរទាំងមូលទេ។ ហេតុអ្វីបានជានាងតាម៉ារជាសាសន៍ដទៃ រៀបរាប់បញ្ចូលនៅក្នុងបញ្ជីពង្សាវតាររបស់ព្រះយេស៊ូវគ្រីស្ទដែរ? នាងតាម៉ារទទួលស្គាល់ថា នាងមានបាប ហើយត្រូវការព្រះអម្ចាស់យេស៊ូវគ្រីស្ទ នាងជឿដល់ព្រះអង្គដែលត្រូវយាងមក។ ដូច្នេះហើយ បានជាឈ្មោះនាងត្រូវរាប់បញ្ចូលជាមួយនឹងបញ្ជីពង្សាវតារនេះដែរ។

"នាងរ៉ាហាប" ជាស្ត្រីសាសន៍ដ៏ទៃទីពីរ ដែលរៀបរាប់បញ្ចូលនៅក្នុងពង្សាវតារនៅក្នុងខប្រាំ។ បើប្រសិនណាជាយើងមើលនៅក្នុងព្រះគម្ពីរយ៉ូស្វេជំពូក២ នាងរ៉ាហាបមិនមានប្រវត្តិល្អទេ។ ប៉ុន្តែនាងរ៉ាហាបបានរាប់បញ្ចូលមកក្នុងបញ្ជីនេះ ពីព្រោះនាងជឿលើសេចក្តីសន្យា ដែលព្រះជាម្ចាស់បានបញ្ជូនគេទៅអោយផ្សាយដំណឹងនៅក្នុងទីក្រុងរបស់នាង ហើយនាងជឿថា ព្រះយេហូវ៉ាជាព្រះដ៏រស់ ហើយជាព្រះដ៏ពិតផង។ "ដោយសារសេចក្តីជំនឿ នោះនាងរ៉ាហាបជាស្រីសំផឹង មិនបានវិនាសទៅជាមួយនឹងពួកអ្នករឹងចចេសឡើយ ពីព្រោះនាងបានទទួលពួកឈ្លបលបដោយមេត្រីចិត្ត" (ហេព្រើរ១១:៣១)។ នាងរ៉ាហាបជឿដល់ព្រះយេស៊ូវគ្រីស្ទ ដូច្នេះបានជាត្រូវរាប់បញ្ចូលមកក្នុងបញ្ជីពង្សាវតាររបស់ព្រះអង្គ។ នាងមិនមែនជាស្ត្រីល្អគ្រប់ល័ក្ខណ៍ទេ ប៉ុន្តែនាងដឹងថាខ្លួនមានបាប ហើយក៏ទទួលជឿដល់ព្រះអម្ចាស់យេស៊ូវ អោយទ្រង់លាងសំអាតបាបរបស់នាង។

"នាងរស់" គឺជាស្ត្រីម្នាក់ទៀត ជាសាសន៍ដ៏ទៃរាប់បញ្ចូលមកក្នុងពង្សាវតារនៅក្នុងខប្រាំដែរ។ នាងរស់ជាស្ត្រីទន់ភ្លន់មានអត្តចរិកល្អ ហើយជាស្ត្រីដែលកម្រមានអ្នករកកំហុសនាងឃើញណាស់។ នាងជាសាសន៍ម៉ូអាប់ បើតាមមើលនៅក្នុងព្រះគម្ពីរចោទិយកថា២៣:៣។ បើតាមច្បាប់ សាសន៍ដ៏ទៃមិនមានសិទ្ធិចូលមកថ្វាយបង្គំនៅក្នុងសាលាប្រជុំទេ។ ទោះបីច្បាប់បានចែងយ៉ាងដូច្នេះក៏ដោយ មានបុរសម្នាក់ជាសាសន៍អ៊ីស្រាអែលឈ្មោះបូអូសដណ្តឹងនាងយកធ្វើជាប្រពន្ធ។ លោកដណ្តឹងនាងរស់ ពីព្រោះនាងរស់ជឿដល់សេចក្តីសន្យា ដែលព្រះអម្ចាស់មានបន្ទូលមកកាន់នាង ហើយនាងសុខ

ចិត្តដើរតាមម្តាយដែលជឿដល់ព្រះជាម្ចាស់។ នាងត្រូវរាប់បញ្ចូលមកក្នុងបញ្ជីរបស់ព្រះយេស៊ូវគ្រីស្ទ ពីព្រោះនាងជឿដល់ព្រះអម្ចាស់ជាអង្គសង្គ្រោះ។

នាង "បៀសេបា" ជាស្រីសាសន៍ដ៏ទៃដែរ ហើយនាងជាអតីតភរិយារបស់អ៊ូរី ជាមេទ័ពរបស់ស្តេចដាវីឌ (៦៦) ឈ្មោះនាងត្រូវរាប់បញ្ចូលមកក្នុងបញ្ជីពង្សាវតារព្រះយេស៊ូវគ្រីស្ទ ដោយសារដាវីឌជាប្តីក្រោយរបស់នាង។ ដាវីឌបានប្រព្រឹត្តិអំពើបាបដោយផិតក្បត់នឹងនាង។ ប៉ុន្តែព្រះជាម្ចាស់មិនបានបោះបង់ចោលដាវីឌ ដោយសារតែក្សត្រនេះ បានប្រព្រឹត្តិអំពើបាបបែបនោះទេ។ ក្សត្រនេះបានត្រឡប់មកលន់តួ ហើយជឿដល់ព្រះអម្ចាស់ ទុកចិត្តព្រះអម្ចាស់ ទាំងបម្រើព្រះអម្ចាស់អស់ពីចិត្តផងដែរ។ ដោយសារលោកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រះអង្គក៏នាំដាវីឌចូលមកក្នុងក្រោលរបស់ចៀមទ្រង់វិញ។ ដូច្នេះហើយ ដោយសារនាងបៀសេបាត្រូវជាភរិយារបស់ស្តេចដាវីឌ នាងត្រូវរាប់បញ្ចូលក្នុងពង្សាវតាររបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ថ្វីដ្បិតនាងជាសាសន៍ដ៏ទៃក៏ដោយ។

ពេលនេះ យើងឃើញមានរឿងសំខាន់មួយទៀត ក្នុងបញ្ជីពង្សាវតារនេះ។ បើប្រសិនណាជាលោកអ្នកយកបញ្ជីពង្សាវតារនៅក្នុង១របាក្សត្រ៣:១១-១២ មកប្រៀបធៀបជាមួយនឹងខប្រាំបី នៅក្នុងម៉ាថាយជំពូកមួយនេះយើងឃើញថា ឈ្មោះអ័ហាស៊ីយ៉ា យ៉ូអាស និងអ័ម៉ាស៊ា មិនបានរាប់បញ្ចូលនៅក្នុងបញ្ជីពង្សាវតារនេះទេ។

ដូច្នេះ សេចក្តីទាំងនោះសបញ្ជាក់អោយយើងឃើញថា នៅក្នុងបញ្ជីពង្សាវតាររបស់ព្រះយេស៊ូវគ្រីស្ទនេះ មិនបានរៀបរាប់មនុស្សរៀងរាល់រូបជាបន្តបន្ទាប់គ្នាជា

រឿងរហូតកន្លងមកទេ។ រីឯបញ្ជីពូជពង្សរបស់មនុស្សលោក រស់មុនគ្រាមហាជំនន់ដែលមានបរិយាយនៅក្នុងព្រះគម្ពីរលោកុប្បត្តិក៏មានលក្ខណៈយ៉ាងដូច្នោះដែរ។ មានមនុស្សជាច្រើនដែលមិនបានយកមករៀបរាប់នៅក្នុងបញ្ជីពង្សាវតារទេ ប៉ុន្តែលោកទាំងនោះក៏ជាផ្នែកមួយនៃបញ្ជីនៅក្នុងពង្សាវតារនោះដែរ។ ឈ្មោះអេសា ដែលមានរៀបរាប់នៅក្នុងខប្រាំបីនេះ មាននិយាយតិចតួចណាស់ នៅក្នុងព្រះគម្ពីរទាំងមូល។ យើងឃើញមានឈ្មោះគាត់និយាយនៅក្នុងព្រះគម្ពីរ ប៉ុន្តែមិនបានឃើញថ្ងៃ ខែ ឆ្នាំដែលគាត់រស់នៅក្នុងខគម្ពីរទេ។

**១០ អេសេគាសបង្កើតម៉ាន៉ាសេ។បង្កើតអាំម៉ូន ។បង្កើតយ៉ូសៀស**
**១១ យ៉ូសៀសបង្កើតយេកូនាស ហើយនឹងបងប្អូនគាត់ នៅគ្រាដែល**
**ត្រូវនិរទេសទៅស្រុកបាប៊ីឡូន (ម៉ាថាយ១:១០-១១)។**

ក្នុងខ១១ លោកម៉ាថាយមិនបានយកឈ្មោះយេហូយ៉ាគីម យកមករាប់ទេ ប៉ុន្តែលោកបានយកឈ្មោះយេកូនាសមករាប់ជំនួសវិញ។ យើងយកចិត្តទុកដាក់ជាមួយនឹងឈ្មោះយេកូនាស ពីព្រោះយេកូនាសជាខ្សែស្រឡាយបង្កើតលោកយ៉ូសែបដែលជាជាងឈើនោះមក។ ប៉ុន្តែព្រះអង្គសន្យានៅក្នុងគម្ពីរយេរេមា២២:២៤ និងខ៣០យ៉ាងដូច្នេះថា "ព្រះយេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ ទោះបើយេកូនាសជាបុត្រយេហូយ៉ាគីម ស្តេចសាសន៍យូដាជាចិញ្ចៀនត្រានៅដៃស្តាំអញក៏ដោយ គង់តែអញនឹង

កន្ត្រាក់ចេញទៅដែរ ខ៣០...ត្រូវកត់ឈ្មោះរបស់មនុស្សនេះថាជាគ្មានកូន ជាមនុស្ស ដែលនឹងមិនចំរើនក្នុងជំនាន់របស់ខ្លួនឡើយ ដ្បិតនឹងគ្មានពូជពង្សគេណាមួយ ដែលនឹង អាចអង្គុយលើបល្ល័ង្កនៃដាវីឌ ហើយគ្រប់គ្រងលើស្រុកយូដាបានទៀតឡើយ”។ ហេតុអ្វី ក៏យេកូនាសមានឈ្មោះនៅក្នុងបញ្ជីពង្សាវតាររបស់ព្រះយេស៊ូវគ្រីស្ទ បើព្រះជាម្ចាស់ ទ្រង់មានបន្ទូលថា ឈ្មោះនេះមិនអាចមានពូជពង្សដែលអង្គុយនៅលើបល្ល័ង្កនៃដាវីឌ បាននោះ។ យ៉ូសែបដែលជាឪពុកចិញ្ចឹមរបស់ព្រះយេស៊ូវគ្រីស្ទ កើតមកពីត្រកូល យេកូនាសនេះ។ លោកម៉ាថាយបានជំរាបច្បាស់លាស់ណាស់ នៅត្រង់នេះថា យ៉ូសែប មិនមែនជាឪពុកបង្កើតរបស់ព្រះយេស៊ូវគ្រីស្ទទេ។ យ៉ូសែបគ្រាន់តែជាអ្នកបំពេញតួនាទី ផ្នែកផ្លូវច្បាប់អត្រានុកូលដ្ឋានថា ព្រះយេស៊ូវគ្រីស្ទជាកូនរបស់យ៉ូសែប។ យ៉ូសែបជាកូន យេកូនាស ត្រូវរាប់បញ្ចូលមកក្នុងពង្សាវតារនៃកំណើតពីព្រះយេស៊ូវគ្រីស្ទត្រង់ដែលថា យ៉ូសែបគឺប្តីរបស់នាងម៉ារា ឯនាងម៉ារាទៀតសោត ជាម្តាយរបស់ព្រះយេស៊ូវគ្រីស្ទនោះ មានខ្សែស្រឡាយពីក្សត្រដាវីឌផ្ទាល់មកតែម្តង។ ព្រះយេស៊ូវគ្រីស្ទមិនមែនជាពូជរបស់ យ៉ូសែបទេ ហើយទ្រង់ក៏មិនមែនជាពូជរបស់យេកូនាសដែរ។ ប៉ុន្តែ ថ្វីដ្បិតយ៉ូសែបមិន បានបង្កើតព្រះយេស៊ូវមកក៏ពិតមែន យ៉ូសែបក៏ជាខ្សែស្រឡាយរបស់ដាវីឌ តាមរយៈកូន ទ្រង់ផ្សេងទៀតដែលត្រូវជាសាច់ញាតិ នឹងខ្សែស្រឡាយរបស់នាងម៉ារាដែរ។ បើយើង ពិចារណាមើលគម្ពីរលូកា នាងម៉ារាត្រូវជាខ្សែស្រឡាយរបស់ស្តេចដាវីឌតាមរយៈកូន ប្រុសរបស់លោកឈ្មោះណាថាន់។ រីឯយ៉ូសែបវិញ ជាខ្សែស្រឡាយរបស់ដាវីឌតាមរយៈ ក្សត្រសាឡូម៉ូន។ ដូច្នេះ ដោយសារនាងម៉ារា និងយ៉ូសែបជាពូជរបស់ដាវីឌទាំងពីរនាក់

បានជាគេត្រូវធ្វើដំណើរទៅបេថ្លេហិម ដើម្បីចុះបញ្ជីនៅទីនោះ។ រឿងខាងលើដែលយើងបញ្ជាក់នេះ ជារឿងស្មុគស្មាញ ប៉ុន្តែយើងទាំងអស់គ្នា ត្រូវតែតាមដានរកដោះការជំពាក់វាក់វិននោះ ដើម្បីអោយឃើញថា បញ្ជីពង្សាវតាររបស់ព្រះយេស៊ូវគ្រីស្ទមានរាប់បញ្ចូលយ៉ូសែប និងម៉ារាជាមួយគ្នាដែរ។